# ព្រះវិហារវត្តកោះប៉ែននិងសិល្បៈគំនូរដែលគង់វង្សរស់ពីសង្គ្រាម

វត្តពោធិវ័ន ដែលគេស្គាល់ជាទូទៅហៅថា "វត្តកោះប៉ែន" ស្ថិតនៅលើកូនកោះតូចមួយនាកណ្ដាលដងទន្លេមេគង្គ នៅក្នុងភូមិកោះប៉ែន "គ" ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានចម្ងាយប្រមាណ៣ គីឡូម៉ែត្រពីទីរួមខេត្ត ដោយធ្វើដំណើរឆ្លងកាត់ស្ពានកោះប៉ែន។ បើតាមកំណត់ត្រាសង្ខេបប្រវត្តិនៃវត្តនេះបញ្ជាក់ថា ទីវត្តកោះប៉ែនបានចាប់ផ្ដើមកសាងឡើងក្នុងឆ្នាំ១៧៩៥ ដោយគំនិតផ្ដួចផ្ដើមរបស់លោកតា អ៊ុង មី ព្រមទាំងព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្ត។ ប៉ុន្តែកាលដើមឡើយ សំណង់នៅក្នុងវត្តនេះចាប់ផ្ដើមពីត្រឹមសាឡុំឈើប្រក់ស្បូវ សម្រាប់គោរពបូជាបណ្ដោះអាសន្ន។ លុះក្រោយមកទើបមានព្រះចៅអធិការព្រះនាម ឯក ពៅ (១៨៨៥-១៩២៨) និងព្រះចៅអធិការព្រះនាម ព្រហ្ម គិត (១៩២៥-១៩៤៥) បានដឹកនាំពុទ្ធបរិស័ទរៀបចំកសាងព្រះវិហារ ដោយបានកសាងឡើងជាច្រើនដំណាក់កាលបន្តបន្ទាប់ រហូតបានរួចរាល់ជាស្ថាបត្យ គង់វង្សនៅដូចឃើញសព្វថ្ងៃ (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តកោះប៉ែន (មើលពីជ្រុងឦសាន)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមការស្រាវជ្រាវរបស់លោកស្រី *Danielle* និងលោក *Dominique-Pierre Guéret* បញ្ជាក់ថា ព្រះវិហារវត្តកោះប៉ែនចាប់ផ្តើមកសាងឡើងរវាងឆ្នាំ១៩៣៥-១៩៣៦។[១] ព្រះវិហារនេះជាសំណង់បេតុងដ៏រឹងមាំ និងល្អប្លែកតាមដងទន្លេ ដែលគេយល់ថាជាការវិវឌ្ឍថ្មីនៃស្ថាបត្យកម្មនៅក្នុងរាជ្យ **ព្រះករុណា ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស (ព្រះបរមខត្តិយកោដ្ឋ)**។ ព្រះវិហារកសាងនៅលើខឿនខ្ពស់ត្រដែតពីរថ្នាក់ ដែលទំនងដោយហេតុផលនៃការការពាររបបទឹកទន្លេ ហើយមានបណ្តោយប្រវែង២៦ម៉ែត្រ ទទឹងប្រវែងជាង១១ម៉ែត្រកន្លះ និងមានជណ្តើរឡើងនៅគ្រប់ទិសទាំងបួន ព្រមទាំងមានទ្វារចេញចូលចំនួន១៨ (រូបលេខ២)។ នៅលើផ្ទាជុំវិញនៃខឿនថ្នាក់ទីមួយ មានបញ្ចុះសន្ទឹកសីមាឆ្លាក់រូបទេពប្រណម្យ(?) ព័ទ្ធជុំវិញតាមទិសតូចនិងទិសធំទាំងប្រាំបី។ សូមបញ្ជាក់ថា សន្ទឹកសីមាជាវត្ថុដែលកំណត់ថាទីនេះជាទីសក្ការៈ ដែលជាទូទៅមានចំនួនប្រាំបួនគឺ មួយនៅមុខបល្ល័ង្កព្រះហៅថាសីមាឥន្ទ្រកីល ចាត់ទុកថាសំខាន់ជាងគេ[២] និងសីមាប្រាំបីទៀតស្ថិតនៅតាមទិសតូចនិងទិសធំទាំងប្រាំបីដូចបានរៀបរាប់ខាងលើ (រូបលេខ៣)។





*រូបលេខ២-៣ ព្រះវិហារវត្តកោះប៉ែនសង់លើខឿនខ្ពស់ត្រដែត និងសន្ទឹកសីមាជុំវិញព្រះវិហារ*

យោងតាមសាវតារវត្តបញ្ជាក់ថា ក្នុងសម័យខ្មែរក្រហមព្រះវិហារវត្តកោះប៉ែនបានបិទទ្វារចោល មិនប្រើធ្វើឃ្លាំងដូចព្រះវិហារដទៃទេ ហើយក្នុងទសវត្សរ៍១៩៩០ ព្រះសង្ឃនិងពុទ្ធបរិស័ទបានជួសជុលឡើងវិញ ទុកជាតំណាព្រះសាសនាគោរពបូជាដល់សព្វថ្ងៃ។ ចំពោះរចនាសម្ព័ន្ធដំបូលព្រះវិហារ គឺកសាងឡើងក្នុងទម្រង់ជាព្រះវិហារជហ្វាបួន ខ្ពស់

---

[១] Danielle & Dominique-Pierre Guéret; 2017, p. 112

[២] ស៊ីយ៉ុន សុភារិទ្ធ, ២០១០-២០១១, ទំ.៥៦-៥៩

អត្ថបទដោយៈ ហៀន សុវណ្ណមរកត

ត្រដែត ហើយផ្ទៃដំបូលមានជម្រាលចុះជាថ្នាក់ៗសងខាង ប្រក់ក្បឿងស្រកាលេញ។ នៅលើហោជាងមុខ និងក្រោយលម្អដោយសិល្បៈចម្លាក់ពុម្ពស៊ីម៉ងត៍។ លើផ្ទៃហោជាងទាំងពីរនេះមានរចនារូបព្រះឥន្រ្ទគង់លើដំរីឰរាវត[៣]នៅចំកណ្តាល ហើយផ្នែកខាងក្រោមជារូបរាហូខ្ជាក់កម្រងក្បាច់រាយពេញផ្ទៃហោជាង (រូបលេខ៤-៥)។ សូមបញ្ជាក់ថារចនាសម្ព័ន្ធដំបូលនិងការលម្អផ្សេងៗនេះបានជួសជុលថ្មីកាលពីឆ្នាំ២០១៥។




*រូបលេខ៤-៥ ការលម្អលើហោជាងទាំងពីរនៃព្រះវិហារ*

ដោយឡែកនៅផ្នែកខាងក្នុងព្រះវិហារមានសសរបេតុងមូលចំនួន១២ដើម ទ្រផ្នែករចនាសម្ព័ន្ធដំបូលខ្ពស់ស្រឡះ ល្វែងគ្រឹះនៅកណ្តាល និងមានរបៀងអមសងខាងដូចព្រះវិហារផ្សេងៗដែរ តែព្រះវិហារនេះនៅរក្សាកម្រាលឥដ្ឋពណ៌តាំងពីដើមដដែល។ ចំណែកនៅចុងល្វែងគ្រឹះផ្នែកខាងលិចមានបល្ល័ង្កខ្ពស់តម្កល់ព្រះដ៏ធំ (រូបលេខ៦)។ រីឯនៅផ្នែកខាងក្រោយបល្ល័ង្កនោះ មានចំណារបញ្ជាក់ព្រះនាម និងឈ្មោះព្រះសង្ឃ និងពុទ្ធបរិស័ទមានចិត្តសទ្ធាសាងព្រះពុទ្ធរូប តាំងពីសាសនា២៤៨៣ នៅក្នុងឆ្នាំរោង ត្រូវនឹងឆ្នាំ១៩៤០។ បើផ្អែកតាមកាលបរិច្ឆេទនេះមានន័យថា ក្រោយចាប់ផ្តើមកសាងព្រះវិហារប្រហែល៤ឆ្នាំទើបបានកសាងព្រះបដិមាព្រះដ៏ធំ។ ប៉ុន្តែអ្វីជាការកត់សម្គាល់គេឃើញព្រះបដិមាតម្កល់លើបល្ល័ង្កចំនួនប្រាំពីរព្រះអង្គ ស្ថិតក្នុងឥរិយាបថសិល្បៈតែមួយ ពោលគឺគង់ព្នែនសមាធិ ឬហៅថាកាយវិការផ្ចាញ់មារទាំងប្រាំពីរព្រះអង្គ។ ទន្ទឹមនេះបើពិនិត្យមើលក្បាច់លម្អនៅជុំវិញបាល្ល័ង្កនោះសោត គឺជាក្បាច់សិល្បៈចម្លាក់ពុម្ពស៊ីម៉ងត៍ ដែលទំនងជាការជួសជុលកែលម្អជាថ្មីក្នុងពេលក្រោយដែរ។

---

[៣] សូមអានបន្ថែម៖ ជី រដ្ឋា, ២០០៧-២០០៨,ទំ.៧៨-៨១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៦ ទិដ្ឋភាពផ្នែកខាងក្នុងព្រះវិហារ និងព្រះជីវ៍ធំ

ចំពោះសិល្បៈគំនូរលើជញ្ជាំងខាងក្នុងព្រះវិហារ គេឃើញគូរជារបៀបគំនូរបុរាណ គូរប្រធានបទធំពីរគឺ រឿងពុទ្ធប្រវត្តិគូរជាផ្ទាំងធំៗនៅជួរខាងលើ និងរឿងជាតកគូរនៅជួរខាងក្រោម។ គំនូរពុទ្ធប្រវត្តិរៀបរាប់ដំណើររឿងចាប់ពីផ្នែកខាងកើតនៃជញ្ជាំងខាងត្បូង តែផ្ដើមរឿងសង្ខេបយកពីត្រឹមព្រះអង្គទតរាហុលកុមារ មុនយាងចេញបួសទាំងកណ្ដាលអាធ្រាត្រ។ ដំណើររឿងនេះបន្តលើជញ្ជាំងខាងត្បូង ទៅខាងលិច និងខាងជើង ទៅតាមទិសប្រទក្សិណ រហូតមកបញ្ចប់នៅជញ្ជាំងខាងកើត ដែលជាផ្ទាំងគំនូរធំជាងគេគូរត្រង់ព្រះអង្គបរិនិព្វាន (រូបលេខ២៧-៨)។ ឯគំនូររឿងជាតកនៅជួរខាងក្រោម គឺចាប់ផ្ដើមគូរពីរឿងព្រះវិធូរបណ្ឌិតនៅលើជញ្ជាំងខាងកើត (ក្រោមព្រះអង្គបរិនិព្វាន) ហើយបន្ទាប់មកគឺរឿងព្រះវេស្សន្តរ និងបន្តមកទៀតគូររឿងជាតកផ្សេងៗចម្រុះគ្នា ពុំតាមលំដាប់លំដោយឡើយ។[៤] ប៉ុន្តែអ្វីជាការកត់សម្គាល់ក្នុងគំនូរជាតកនីមួយៗ គឺតែងគូរបញ្ចូលទិដ្ឋភាពសង្គមជាក់ស្ដែងទៅក្នុងនោះដូចជា វាំងវិមាន ឬបុស្បុកជាសំណង់ស្ថាបត្យកម្មខ្មែរ ក្រុមទាហាន

[៤] ជាទូទៅរឿងជាតក គេច្រើនគូរតាមលំដាប់ជាតិគឺ តេមិយជាតក មហាជនកជាតក សុវណ្ណសាមជាតក នេមិរាជជាតក មហោសថជាតក ភូរិទត្តជាតក ចន្ទកុមារជាតក នារទព្រហ្មជាតក វិធូរបណ្ឌិតជាតក និងវេស្សន្តរជាតក។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ហ្លួង ទាហានបាពាំង និងភ្លេង ល្បែងរបាំផ្សេងៗជាដើម (រូបលេខ៩-១០)។ ពិសេសជាងនេះទៀតនៅលើជញ្ជាំងខាងលិច  គេបានគូរបញ្ចូលតួអង្គក្នុងរឿងទេពកថាមួយចំនួនដូចជា ហនុមាន កិន្នរ គ្រុឌ និងទេវតា។ ពាក់ព័ន្ធនឹងគំនូរទាំងអស់ខាងលើនេះ អ្នកស្រាវជ្រាវយល់ថាគូររវាងឆ្នាំ១៩៣៦ និង ១៩៤២។[៥] បើផ្អែកតាមចំណារលើជញ្ជាំងខាងកើតផ្នែកខាងក្រោមគំនូរត្រង់អន្ទើព្រះអង្គទ្រង់បរិនិព្វានបញ្ជាក់ច្បាស់ថា "ព្រះពុទ្ធសករាជកន្លងទៅបាន២៤៨៥ព្រះវស្សា ឆ្នាំមមី ចត្វាស័ក លោកគ្រូព្រះ ឥន្ទ ដ្ឋោត(?) កើតដួងចិត្តតម្លាសទ្ធាបានបបួលអស់ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា កុមារី កុមារា កសាងគំនូរនៅថ្ងៃសៅរ៍ប្រាំបួនរោច ខែភទ្របទ ឆ្នាំមមី ចត្វាស័ក" ហើយនៅលើជញ្ជាំងខាងត្បូងចុងខាងលិច ក៏បានកត់ឆ្នាំដូចគ្នាដែរ ហើយថែមទាំងបញ្ជាក់ថា "លោកគ្រូនាមឈ្មោះ ណោ[៦] ជាអ្នកដើមគំនិត" ដែលកាលបរិច្ឆេទនេះគឺត្រូវនឹងឆ្នាំ១៩៤២ ប្រាកដមែន។




រូបលេខ៧-៨ គំនូរពុទ្ធប្រវត្តិត្រង់អន្ទើព្រះពុទ្ធបរិនិព្វាន ព្រះអង្គទទួលចង្ហាន់នាយចុន្ទ និងព្រះអង្គប្រឈូន)




រូបលេខ៩-១០ គំនូរខ្លះក្នុងរឿងជាតក

[៥] Danielle & Dominique-Pierre Guéret; 2017, p. 112

[៦] បើតាមសាវតារវត្ត ព្រះអង្គជាព្រះចៅអធិការទី៥ នាម ឈុត ណោ (ឆ្នាំ១៩៤៥-១៩៥៧)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សិល្បៈគំនូរលើពិតានឈើខាងលើល្វែងគ្រឹះ មានបីផ្នែកគឺ ត្រង់លើព្រះដីរ៍ គូរផ្ទាំងពន្លឺពណ៌រង្សី(?) ហើយបន្ទាប់មកគូរត្រង់ព្រះអង្គសម្តែងបដិហារ្យលើចុងស្វាយ នៅក្រុងសាវត្ថី (រូបលេខ១១) រួចយាងទៅសម្តែងធម៌នៅស្ថានតាវតឹង្ស (រូបលេខ១២)។ គំនូរនេះហាក់ប្លែកពីវត្តដទៃ ដែលនិយមគូរព្រះអាទិត្យ និងព្រះចន្ទ្រ។[៧] គំនូរលើពិតាននេះ មានលក្ខណៈប្លែកពីគំនូរលើជញ្ជាំងជុំវិញ ហើយចុះកាលបរិច្ឆេទពុទ្ធសករាជ២៤៨៧(ត្រូវនឹងឆ្នាំ១៩៤២)។ ប៉ុន្តែលោកស្រី *Danielle* និងលោក *Dominique-Pierre Guéret* យល់ថាគំនូរនេះគូរក្នុងឆ្នាំ១៩៦០។[៨]



រូបលេខ១១-១២ គំនូរលើពិតាន គូរត្រង់ព្រះអង្គសម្តែងបដិហារ្យ និងសម្តែងធម្មទេសនានៅស្ថានត្រៃត្រឹង្ស

រួមសេចក្តីមក ព្រះវិហារវត្តវត្តកោះប៉ែនជាសិល្បៈស្ថាបត្យកម្មដ៏មានតម្លៃ ដែលមិនត្រឹមតែបង្ហាញពីការវិវឌ្ឍសំណង់ពុទ្ធសាសនាក្នុងសង្គមប៉ុណ្ណោះទេ តែព្រះវិហារនេះមានសិល្បៈគំនូរលើជញ្ជាំង និងលើពិតាន ដែលចារឹកកាលបរិច្ឆេទតាំងទសវត្សរ៍ទី១៩៤០។ សិល្បៈគំនូរដ៏ល្អវិចិត្ររៀបរាប់ពីរឿងពុទ្ធប្រវត្តិ រឿងជាតកនានា ហើយថែមទាំងបញ្ចូលនូវទិដ្ឋភាពសង្គមខ្មែរជាក់ស្តែងដោយអន្ទើខ្វះផង។ មិនតែប៉ុណ្ណោះ សំណង់ព្រះវិហារនេះជាតឹងតាងមត៌កដែលដ៏កម្រដែលឆ្លងកាត់សម័យកាលសង្គ្រាមគង់វង្សមកដល់សព្វថ្ងៃ៕

[៧] សាន ផល្លា, ២០០៧, ទំ. ១៣៦

[៨] Danielle & Dominique-Pierre Guéret; 2017, p. 112

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ជី វដ្ឋា

២០០៧-២០០៨, "ព្រះឥន្ទ្រនៅក្នុងអារ្យធម៌ខ្មែរ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៣, ទំ.៧៨-៨១, Friends of Khmer Culture, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រ៉ៃយំ, ភ្នំពេញ

ស៊ីយ៉ុន សុភារិទ្ធ

២០១០-២០១១, "ចម្លាក់រឿងលើសីមា", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៦, ទំ.៥៦-៥៩, Friends of Khmer Culture, ភ្នំពេញ

Daniell Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត